# ស្វែងយល់ខ្លះៗអំពីរាជធានីសម័យអង្គរ

## គ.ស៨០២ដល់១២៣១ (ភាគ១)

ការផ្លាស់ប្តូរសម័យកាល និងការស្ថាបនាទីក្រុងដំបូងៗនៃសម័យអង្គរ គឺចាប់ផ្តើមឡើងដោយព្រះបាទជ័យវរ្ម័នទី២ (គ.ស៨០២ដល់ គ.ស៨៣៦) ដោយមានការតាំងរាជធានីជាច្រើននៅត្រើយខាងជើងឈៀងខាងលិចបឹងទន្លេសាប។ គេអាចដឹងតាមរយៈសិលាចារឹកថា ព្រះបាទជ័យវរ្ម័នទី២បានស្ថាបនារាជធានីសំខាន់មួយនៅលើខ្នងភ្នំឈ្មោះ **មហេន្ទ្របវ៌ត**[១] (ភ្នំគូលេន) និងតំបន់មួយទៀតដែលលោកសឺដេសគិតថា ជាកន្លែងដែលព្រះអង្គគង់នៅ២ដង និងសុគត គឺហរិហរាល័យ[២] (តំបន់រលួស សៀមរាប) (រូបលេខ១)។ ការគង់នៅតំបន់ហរិហរាល័យ គឺបានបន្តរហូតដល់ស្តេច២អង្គទៀត គឺព្រះបាទជ័យវរ្ម័នទី៣ គ.ស៨៣៤ដល់៨៧៧ (បុត្រារបស់ជ័យវរ្ម័នទី២) និងព្រះបាទឥន្ទ្រវរ្ម័នទី១ គ.ស៨៧ ដល់៨៨៩ (ក្មួយខាងប្រពន្ធរបស់ព្រះបាទជ័យវរ្ម័នទី២)។ ក្នុងតំបន់ហរិហរាល័យនេះ មានប្រាសាទបែបសាសនានិងបុព្វការីជនមួយចំនួន ហើយទីតាំងដែលគេគិតថាអាចជារាជវាំងនោះ គឺស្ថិតនៅក្នុងបរិវេណកំពែងរបស់ប្រាសាទព្រៃមន្ទីរ (ពាក្យមន្ទីរនេះមានន័យថារាជវាំង)។[៣] ក្រោយមកបុត្រារបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ ព្រះនាម យសោវរ្ម័នទី១ (គ.ស៨៨៩ដល់៩១០) បានផ្លាស់ប្តូរទីតាំងរាជធានីពីហរិហរាល័យ ទៅយសោធរបុរៈ[៤] (រូបលេខ២) ដោយមានផ្ចិតកណ្តាលហៅថា យសោធរបវ៌ត ឬយសោធរគីរី (ភ្នំបាខែង) (រូបលេខ៣)។[៥] ឈ្មោះរាជធានី យសោធរបុរៈ នេះត្រូវបានប្រើប្រាស់ និងគោរពដោយស្តេចក្រោយមកទៀតរហូត

---

[១] Chhany Sak. Humphry 2005:93

[២] G. Cœdès 1937:187-188

[៣] Savaros Pou 2002:264

[៤] Louis Finot 1915:72

[៥] យសោធរបុរៈជាឈ្មោះធានី ឬរាជធានី ដែលសាងឡើងដោយព្រះបាទយសោវរ្ម័នទី១។ ចំណែកភ្នំបាខែងសព្វថ្ងៃជាផ្ចិតរបស់រាជធានី ហើយភ្នំនោះមានឈ្មោះដើមជាភាសាសំស្រ្កឹតហៅថា យសោធរបវ៌ត ឬយសោធរគីរី និងឈ្មោះជាភាសាខ្មែរហៅថា វ្នំកន្តាល (ភ្នំកណ្តាល) គឺកណ្តាលកំពែងធានី និងកណ្តាលភ្នំ២ផ្សេងទៀតគឺភ្នំក្រោម និងភ្នំបូក។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ដល់សម័យអាណាចក្រអង្គរបានបញ្ចប់ ដោយការផ្លាស់ប្តូររាជធានីមកតំបន់ខាងត្បូងបឹងទន្លេសាបវិញ (ស្រីសន្ធរ លង្វែក ឧត្តុង្គ និងចតុមុខ)។

ក្នុងសម័យអាណាចក្រអង្គរ មានព្រឹត្តិការណ៍មួយដែលគួរឱ្យកត់សម្គាល់ គឺការផ្លាស់ប្តូរ និងបោះបង់ចោលរាជធានីយសោធរបុរៈដោយព្រះបាទជ័យវរ្ម័នទី៤ (គ.ស៩២៨ ដល់៩៤២) ទៅតំបន់ខាងជើងភ្នំគូលេន មានឈ្មោះថា ឆោកគគ្យារ[៦]/ឆោកគគីរ (កោះកេរ) (រូបលេខ២)។ ក្រោយពីការចូលទិវង្គត់របស់ព្រះបាទជ័យវរ្ម័នទី៤ រាជធានីឆោកគគ្យារត្រូវបានបោះបង់ ដោយសារព្រះបាទរាជេន្ទ្រវរ្ម័នទី២ (គ.ស៩៤៤ដល់៩៦៨) ជាកូនដើមរបស់មហេសីព្រះ បាទជ័យវរ្ម័នទី៤[៧] បានយាងត្រឡប់មកតាំងរាជធានីនៅយសោធរបុរៈវិញ។

តាមសិលាចារឹកមួយចំនួនបានបង្ហាញថា ព្រះបាទរាជេន្ទ្រវរ្ម័នបានស្តារឡើងវិញនូវរាជធានីហេដ្ឋារចនាសម្ព័ន្ធនានារបស់យសោធរបុរៈដែលបានកក់ស្ទះ ហួតហែង ស្ទើក្លាយជាវាលហស្ថាន។ នៅពេលនោះព្រះអង្គបានអោយគេស្ថាបនារាជវាំងថ្មី១នៅខាងជើងយសោធរគីរី ដែលស្ថិតនៅក្នុងរាជធានីយសោធរបុរៈដដែល ដែលរាជវាំងនោះអាចមានឈ្មោះថា ចតុទ្វារ[៨] ដែលមានបង្ហាញភាគច្រើនក្នុងសិលាចារឹកសតវត្សទី១១។ នេះមានន័យថា ព្រះអង្គបានគោរពយ៉ាងស្មោះស្ម័គដល់កិត្តិនាមព្រះបាទយសោវរ្ម័ន និងរាជធានីដំបូងរបស់ព្រះអង្គ ដោយពុំបានកែប្រែឈ្មោះថ្មីរបស់រាជវាំងតាមព្រះនាមរបស់ព្រះអង្គឡើយ។ ប៉ុន្តែ បើយើងសិក្សាលើសិលាចារឹកមួយចំនួនក្នុងសតវត្សទី៩-១០ បង្ហាញថាព្រះបាទយសោវរ្ម័នទី១ ហាក់បីដូចជាបានស្ថាបនារាជវាំងមួយរួចហើយនៅតំបន់ជុំវិញរាជវាំងអង្គរធំ ព្រោះមានមន្ត្រីមួយចំនួនបានចារសិលាចារឹកនិយាយអំពីការធ្វើអំណោយដល់ទីប្រាសាទនៅក្នុងយសោធរបុរៈ។ ក្រោយមក ទើបមានការរៀបចំឡើងវិញ និងសាងសង់បន្ថែម ឬរៀបចំឡើងវិញនូវរាជវាំងដែលកសាងដោយព្រះបាទយសោវរ្ម័នទី១។

អ្នកស្រាវជ្រាវភាគច្រើនគិតថា ព្រះបាទរាជេន្ទ្រវរ្ម័នទី២បានកសាងកំពែងរាជធានីថ្មីដោយកាត់ផ្នែកខ្លះរបស់កំពែងរាជធានីយសោធរបុរៈ (រូបលេខ៥)។ យោងតាមសិលា

---

[៦] G. Cœdès & Dupont, P, 1937:406

[៧] G. Cœdès, 1928:136

[៨] ពាក្យនេះ ភាគច្រើនយើងឃើញមានក្នុងសិលាចារឹកក្នុងសតវត្សទី១១ ពិសេសរាជ្យព្រះបាទជ័យវីរវរ្ម័ន និងព្រះបាទសូរ្យវរ្ម័នទី១។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ចារឹកដែលហៅថាចតុទ្វារ រាជធានីថ្មី និងរាជវាំងថ្មីនេះអាចមានច្រកទ្វារចំនួន៤។ ការកសាង ឬរៀបចំក្រុងអាចមិនទាក់ទងនិងសាសនាប៉ុន្មានទេ គឺភាគច្រើនទាក់ទងទៅ និងសោភ័ណភាព និងកិច្ចការពារ។ ចំណុចនេះវាខុសពីការរៀបចំរចនាសម្ព័ន្ធប្រាសាទដែលឧទ្ទិសដល់ទេព ឬទស្សនៈបុគ្គល។ ប៉ុន្តែអ្វីដែលចាំបាច់នោះគឺការរៀបចំកន្លែងធ្វើពិធីសាសនាដ៏សំខាន់មួយ សម្រាប់អភិសេកព្រះអង្គម្ចាស់អោយក្លាយទៅជាស្តេចនៃមនុស្ស និងជាស្តេចនៃទេព[៩] ដែលគេអាចដឹងតាមរយៈសិលចារឹកហៅថា ពិធី ***កម្រតេង ជគត ត រាជ*** ឬលទ្ធិទេវរាជ។ សំណង់បែបនេះ យើងឃើញមានដំបូងនៅរាជធានីមហេន្ទ្របវ៌ត គឺប្រាសាទគ្រួសអារាម រោងចិន(ក្នុងរាជព្រះបាទជ័យវរ្ម័នទី២) បន្ទាប់មក គឺអាចប្រាសាទបាគង (រាជ្យព្រះបាទឥន្ទ្រវរ្ម័នទី១) ប្រាសាទភ្នំបាខែង (រាជ្យព្រះបាទយសោវរ្ម័នទី១) ប្រាសាទធំ កោះកេរ (រាជ្យព្រះបាទជ័យវរ្ម័នទី៤) ប្រាសាទភិមានអាកាស (រាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី២ រហូតដល់ឧទ័យទិត្យវរ្ម័នទី២)។ ការរៀបចំប្រាសាទបែបនេះ គឺជាប្រាសាទដែលនៅចំកណ្តាលក្រុង ឬផ្ចិតនៃរាជធានី ជាពិសេសនោះ គឺជាប្រាសាទតំណាងឱ្យរាជ្យ។

ការកសាងទីក្រុងយសោធរបុរៈដំបូងដោយព្រះបាទយសោវរ្ម័នទី១ មានប្រាសាទភ្នំបាខែង (រូបលេខ៦)[១០] ជាចំណុចកណ្តាល ហៅព្រះអង្គបានហៅភ្នំនោះថា វ្នំកន្តាល[១១] ដែលលោក Victor Goloubew ដើមឡើយបានគិតថាជាប្រាសាទបាយ័ន្ត។[១២] ប៉ុន្តែចំពោះទីតាំងព្រះរាជវាំងរបស់ព្រះអង្គ នៅមិនទាន់មានការស្រាវជ្រាវឱ្យបានច្បាស់នៅឡើយទេ។ វាអាចស្ថិតនៅភាគខាងជើងនៃភ្នំបាខែង ឬក៏ផ្នែកខ្លះក្នុងក្រុងអង្គរធំ។ ក្រោយការយាងត្រឡប់ពីកោះកេរមកវិញ ព្រះបាទរាជេន្ទ្រវរ្ម័នទី២ បានសាងរាជវាំងនៅខាងជើង ដោយឈរត្រង់ជាមួយនិងប្រាសាទមេបុណ្យខាងកើតតាមអ័ក្សលិចកើត។ រាជវាំងចតុទ្វារជាទីតាំងសំខាន់ ហើយស្ទើគ្រប់ស្តេចដែលសោយរាជ្យតែងគង់នៅទីនោះ ទើបរចនាសម្ព័ន្ធមួយចំនួនត្រូវបានកែប្រែ និងបន្ថែម ធ្វើឱ្យពិបាកយល់ និងសន្និដ្ឋានអំពីទម្រង់ដើម។ រចនាសម្ព័ន្ធ

---

[៩] Lawrence Palmer Briggs 1951:83

[១០] httpscollection.efeo.frwswebappcollectionrecord264556

[១១] G. Cœdès 1952:169

[១២] Claude Jacques 2006:27

ចុងក្រោយបង្អស់ដែលយើងអាចមើលឃើញសព្វថ្ងៃនៃទីក្រុង គឺរាជធានីអង្គរធំក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ (គ.ស១១៨១ដល់១២២០)។ ព្រះបាទជ័យវរ្ម័នទី៧ ដើមឡើយជាស្តេចកាន់ហិណ្ឌូសាសនា បានកែប្រែខ្លួនជាពុទ្ធសាសនិកយ៉ាងខ្ជាប់ខ្ជួន ដោយមានការជួយជ្រំជ្រែងពីមហេសីបានស្ថាបនាសំណង់ផ្សេងៗផ្សារភ្ជាប់រវាងពុទ្ធសាសនា និងហិណ្ឌូសាសនា។ ព្រះអង្គបានរៀបចំទីក្រុងឱ្យមានរូបរាងច្បាស់លាស់ ដោយការកសាងកំពែងថ្មបាយក្រៀម និងថ្មភក់យ៉ាងរឹងមាំ មានបរិមាត្រ៩គីឡូម៉ែត្រ (៣គ.មបួនជ្រុង) និងក្លោងទ្វារចំនួន៥។ ក្នុងការកែប្រែទីក្រុងថ្មីនេះ ព្រះអង្គពុំបានយកប្រាសាទភិមានអាកាសជាផ្ចិតកណ្តាលទេ គឺព្រះអង្គបានកសាងប្រាសាទមួយទៀត (អាចកសាងនៅលើប្រាសាទចាស់) គឺប្រាសាទបាយ័ន្ត ស្ថិតនៅចំនុចកណ្តាល ឆ្ពុះគ្នានិងក្លោងទ្វារ៤ ជើង (ទ្វារដីឆ្នាំង)ត្បូង (ទ្វារទន្លេអុំ) លិច (ទ្វារតាកាវ) និងកើត (ទ្វារខ្មោច)។ ក្លោងទ្វារ១ទៀត គឺបិតនៅលើអ័ក្សលិចកើតជាមួយប្រាសាទភិមានអាកាស ដែលអាចជាក្លោងទ្វារចាស់តាំងពីសម័យរាជវាំងចតុទ្វារ គេហៅថា ទ្វារជ័យ។ តាមការស្រាវជ្រាវរបស់លោក Gaucher[១៣] បានរកឃើញថា ក្រុងអង្គរធំត្រូវបានរៀបចំឱហតមានរបៀប ដូចក្រឡាចត្រង្គ (ស្មើដូចគ្នានិងរាជធានីចិនបុរាណ) ដោយមានប្រព័ន្ធប្រឡាយទឹក ឬអូរ និងទំនប់ខ្ពស់ដែលមានសំណង់ផ្ទះ និងប្រាសាទផងដែរ។ ព្រះបាទជ័យវរ្ម័នទី៧បានរៀបចំក្រុងអង្គរធំជារាជធានីសំខាន់ និងរឹងមាំដើម្បីការពារពីសត្រូវ។ ប៉ុន្តែព្រះអង្គបានកសាងប្រាសាទមួយនៅខាងជើងក្រុងនេះ ជាកន្លែងដែលព្រះអង្គទទួលបានជ័យជំនះលើទ័ពចាមចុងក្រោយ គឺប្រាសាទព្រះខ័(ឈ្មោះបច្ចុប្បន្ន) ដោយហៅក្រុងថ្មីរបស់ព្រះអង្គថា នគរជ័យស្រី។ ក្រៅពីរាជធានី យសោធរបុរៈ និងក្រុងអង្គរធំ (មិនដឹងឈ្មោះដើម តែអ្នកស្រាវជ្រាវភាគច្រើនហៅថា យសោធរបុរៈទី៥) និងនគរជ័យស្រី មានប្រាសាទមួយចំនួនទៀតដែលមានឈ្មោះហាក់បីដូចជាក្រុងស្វ័យតមួយ ដូចជាអនិន្ទិតបុរៈ (ប្រាសាទអកយំ) ជាក្រុងមុនសម័យអង្គរ[១៤] កបិលបុរៈ (ប្រាសាទកបិលបូរ) និងទ្វិជេន្ទ្របុរៈ (ប្រាសាទព្រះឥន្ទ្រកោសីយ) [១៥] ជាដើម។

[១៣] Jacques Gaucher 2003

[១៤] Christophe Pottier 2001:122

[១៥] សុខ កែវ សុវណ្ណារ៉ា ២០២០:៣១

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

## អត្ថបទ៖ ស្វែងយល់ខ្លះៗអំពីរាជធានីសម័យអង្គរ

អត្ថបទនេះ គ្រាន់តែជាសេចក្តីសង្ខេបអំពីការកកើតទីក្រុងឬរាជធានីដំបូងនាដើមសម័យអង្គរ និងការផ្លាស់ប្តូរទីតាំងរាជធានីថ្មីៗ ក្នុងសម័យអាណាចក្រអង្គរ។ អត្ថបទក្រោយនឹងលើកយកបង្ហាញលម្អិតអំពីទីក្រុង និងហេដ្ឋារចនាសម្ព័ន្ធក្នុងនីមួយៗ។




រូបលេខ១ ការតាំងរាជធានីនៅមហេន្ទ្របវ៌ត និងប្តូរមកហរិហរាល័យ ដោយព្រះបាទជ័យវរ្ម័នទី២

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ២ ការប្ដូររាជធានីពីហរិហរាល័យទៅយសោធរបុរៈ ដោយព្រះបាទយសោវរ្ម័នទី១




រូបលេខ៣ ការប្ដូររាជធានីពីយសោធរបុរៈទៅឆោកគគ្យរ ដោយព្រះបាទជ័យវរ្ម័នទី៤

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ២៨ ការសន្និដ្ឋានលើទីតាំងរាជធានីយសោធរបុរៈដំបូងកសាងដោយព្រះបាទយសោវរ្ម័នទី១




រូបលេខ២៩ ការសន្និដ្ឋានលើទីតាំងរាជធានីយសោធរបុរៈកែប្រែដោយព្រះបាទរាជេន្ទ្រវរ្ម័នទី២

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៦ ប្រាសាទភ្នំបាខែង ផ្ចិតរាជធានីយសោធរបុរៈដំបូងកសាងដោយព្រះបាទយសោវរ្ម័នទី១

## ឯកសារយោង

សុខ កែវ សុវណ្ណារ៉ា

២០២០. *ប្រាសាទព្រះវិស្ណុ*, ក្នុងអត្ថបទស្រាវជ្រាវថ្មី និងគួរពិចារណា, លេខ២៣, សៀមរាប។

Chhany Sak. Humphry.

2005. *The Sdok Kak Thom Inscription*, Buddhist Institute.

Christophe Pottier.

2001. *Prespectives de la Mission Achéologique Franco-Khmère sur L´ Aménagement du Territoire Angkorien*, in Udaya, No. 2, Phnom Penh, pp.117-132.

Claude Jacques.

2006. *History of Phnom Bakheng Monument*, École pratique des Études, Paris, pp23-40.

G. Cœdès.

1937. *Inscription du Cambodge*, Volume I, Hanoi.

G. Cœdès & Dupont, P.

1937. *Inscription du Prasat Kok Po*, BEFEO, XXXVII, Paris, 1937, pp.379-413.

G. Cœdès.

1928. *La Tradition Généalogigue des Premiers Rois d΄ Angkor d΄ Après les Inscriptions de Yaçovarman et de Rājendravarman*, BEFEO, Tome XXVIII, pp.124-150.

G. Cœdès.

1952. *Inscription du Cambodge*, Volume IV, Paris.

httpscollection.efeo.frwswebappcollectionrecord264556

Jacques Gaucher.

2003. *Premiers Aperçus sur des Éléments de Planification Urbaine à Angkor Thom*, EFEO.

Lawrence Palmer Briggs.

1951. *The Ancient Khmer Empire*, White Lotus, Thailand.

Louis Finot.

1915. *L΄Inscription de Sdok Kak Thom*, BEFEO, Tome XV(2), Paris, pp.53-106.

Savaros Pou.

2002. *Dictionnaire VieuxKhmer-Français-Anglais*, Cedoreck.